មាត្រា២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

# II. ការងារបណ្តាក្រសួង

## ១- ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សេចក្តីជូនដំណឹង

### សេចក្តីជូនដំណឹង លេខ ០៥២ សហវ.សជណ
### ស្តីពីការត្រួតពិនិត្យលតាប័ត្ររថយន្តគ្រប់ប្រភេទ ដែលធ្វើចរាចរក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា

------

យោងតាមការសំរេចរបស់រាជរដ្ឋាភិបាលតាមលិខិតលេខ ២០២៥ សជណ. ពហ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមជូនដំណឹងដល់ម្ចាស់រថយន្តគ្រប់ប្រភេទដែលធ្វើចរាចរ ទូទាំងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា ៖

១- រថយន្តទេសចរណ៍ រថយន្តដឹកអ្នកដំណើរ រថយន្តដឹកជញ្ជូន គ្រប់ផ្លាកលេខត្រូវបិទលតាប័ត្រ រថយន្តពាក់ផ្លាកលេខស៊ីវិលត្រូវទៅទិញលតាប័ត្រ តាមតារាងដែលបានកំណត់រួចហើយ និង ពិន័យ ២០ភាគរយ នៃថ្លៃលតាប័ត្រអំពីការយឺតយូរបន្ថែមទៀត ។ ចំណែករថយន្តពាក់ផ្លាកលេខ <<ខ.ម>> <<ន.ប>> និង <<ភ.ព៩>>ត្រូវទៅទិញលតាប័ត្រតាមតារាងដែល

បានកំណត់ ហើយចាប់ពីថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥ នឹងត្រូវពិន័យ ២០ ភាគរយ នៃថ្លៃលតាប័ត្រអំពីការយឺតយូរបន្ថែមទៀត ។ ចំពោះរថយន្តដែលជាកម្មសិទ្ធិរបស់រដ្ឋដែលមានក្នុងបញ្ជីសារពើភ័ណ្ឌត្រឹមត្រូវ ជាគោលការណ៍ពុំចាំបាច់ទិញលតាប័ត្រតាមតំលៃ ១២.០០០ <<មួយម៉ឺនពីរពាន់>> រៀលទេ ។

២- ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះតទៅ ភ្នាក់ងារគយ និង រដ្ឋាករ ត្រូវសហការជាមួយប៉ូលិស និង កងរាជអាវុធហត្ថជាតិធ្វើការត្រួតពិនិត្យរថយន្តពាក់ផ្លាកលេខស៊ីវិល ។

៣- ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ ត្រូវធ្វើការត្រួតពិនិត្យរថយន្តពាក់ផ្លាកលេខ <<ខ.ម>> និង <<ន.ប>> <<ភ.ព៩>> ....។

នៅពេលត្រួតពិនិត្យ រថយន្តដែលពុំទាន់មានលតាប័ត្រត្រូវទទួលការពិន័យជាប្រាក់ចំនួន ១០០.០០០ <<ដប់ម៉ឺន>> រៀល ហើយទុកពេលអោយម្ចាស់រថយន្តចំនួន ៧ ថ្ងៃដើម្បីទិញលតាប័ត្រ ។ ចំពោះប្រាក់ដែលទទួលបានពីការផាកពិន័យត្រូវបង់ចូលថវិការដ្ឋ និង អនុញ្ញាតអោយដក ១០ <<ដប់>> ភាគរយសំរាប់ជារង្វាន់ដល់អ្នកដែលមានស្នាដៃក្នុងការងារ ។

អាស្រ័យហេតុនេះ សូមម្ចាស់រថយន្តគ្រប់ប្រភេទជ្រាប និង ទទួលអនុវត្តតាមវិធានការខាងលើនេះអោយមានប្រសិទ្ធភាព ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ហត្ថលេខា និង ត្រា

**គាត- ឈន់**

* * *